សង្ខេបគោលនយោបាយស្ដីពី

# ការដោះស្រាយ ការងារថែទាំ និងការងារផ្ទះ ដែលមិនទទួលបាន ប្រាក់កម្រៃនៅកម្ពុជា



ខែកុម្ភៈ ឆ្នាំ២០២៥

## សេចក្ដីផ្ដើម

សមភាពយេនឌ័រមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ប៉ុន្តែការសិក្សាពីមុនៗមក ជារឿយៗតែងមើលរំលងចំពោះធាតុផ្សំមួយ គឺការប្រើប្រាស់ពេលវេលា ជាពិសេសនៅក្នុងរង្វង់មជ្ឈដ្ឋានគ្រួសារ ។ ការស្រាវជ្រាវថ្មីៗបង្ហាញពីគម្លាតយេនឌ័រយ៉ាងខ្លាំងសម្រាប់ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដែលការងារនេះភាគច្រើនបំផុតនៅតែជាការងារទំនួលខុសត្រូវរបស់ស្ត្រី និងក្មេងស្រី។ អតុល្យភាពនេះជាឧបសគ្គចំពោះលទ្ធភាពរបស់ពួកគេក្នុងការទទួលបានការអប់រំ ការងារមានប្រាក់ឈ្នួល និងការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ហេតុដូចនេះជាការអូសបន្លាយបញ្ហាវិសមភាពយេនឌ័រ។ នៅក្នុងប្រទេសកម្ពុជា បទដ្ឋានយេនឌ័រប្រពៃណី គម្លាតសេដ្ឋកិច្ច និងកង្វះហេដ្ឋារចនាសម្ព័ន្ធនានា ធ្វើឲ្យបញ្ហាប្រឈមទាំងអស់នេះកាន់តែមានសភាពធ្ងន់ធ្ងរឡើង។ ទិន្នន័យថ្នាក់ជាតិស្តីពី ការងារថែទាំ និងការងារក្នុងផ្ទះដែលគ្មានប្រាក់កម្រៃ មិនមានការធ្វើបច្ចុប្បន្នភាពឡើយចាប់តាំងពីឆ្នាំ ២០០៤ ដែលធ្វើឲ្យមានចន្លោះប្រហោងធំធេងក្នុងការស្វែងយល់អំពីស្ថានភាពបច្ចុប្បន្នក្នុងការចែករំលែកការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។



ដើម្បីដោះស្រាយបញ្ហានេះ អង្គការអុកស្វាមបានរៀបចំការសិក្សាស្រាវជ្រាវការងារថែទាំគ្រួសារ សាកល្បង ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកិច្ចការនារី ដើម្បីប្រមូល និងវិភាគទិន្នន័យពាក់ព័ន្ធនានា។ ការសិក្សានេះបានប្រើវិធីសាស្ត្រចម្រុះ ដោយផ្សំគ្នារវាងទិន្នន័យបែបបរិមាណដែលបានមកពីការសិក្សាស្រាវជ្រាវលើការប្រើប្រាស់ពេលវេលា និងទស្សនៈយល់ឃើញ ជាមួយនឹងការយល់ដឹងបែបគុណភាពដែលបានមកពីការពិភាក្សាជាក្រុម។ ការសិក្សានេះគ្របដណ្ដប់លើបួនខេត្តរួមមាន ព្រៃវែង សៀមរាប កំពត និងមណ្ឌលគិរី ដែលតំណាងឱ្យបរិបទចម្រុះនៃសេដ្ឋកិច្ចសង្គម និងភូមិសាស្ត្រ។ ការរកឃើញសំខាន់ៗរួមមាន ពេលវេលាជាមធ្យមដែលក្រុមប្រជាសាស្ត្រផ្សេងៗគ្នាបានចំណាយលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ការយល់ដឹងអំពី បទដ្ឋានសង្គមដែលមានឥទ្ធិពលលើលំអាននៃការប្រើប្រាស់ពេលវេលា និងឥទ្ធិពលនៃលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ និងសេវាការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។ ការរកឃើញទាំងនេះមានសារៈសំខាន់សម្រាប់ការតស៊ូមតិ និងការបង្កើតគោលនយោបាយដើម្បីជំរុញសមភាពយេនឌ័រ។

*គំនិត យោបល់ និងមតិនៅក្នុងឯកសារនេះជាទំនួលខុសត្រូវរបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រដ្ឋាភិបាលអៀរឡង់។*

Government of Ireland
International Development Programme

OXFAM

# លទ្ធផលសំខាន់ៗ



ស្ត្រីចំណាយពេល
5ម៉ោង 2នាទ
ក្នុងមួយថ្ងៃ
លើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ

## លំអាននៃការប្រើប្រាស់ពេលវេលា

- **តំណាងលើសលុបរបស់ស្ត្រី នៅក្នុងការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ៖** ស្ត្រីចំណាយពេល 5 ម៉ោង និង 2 នាទីក្នុងមួយថ្ងៃលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ បើធៀបនឹងបុរស ដែលចំណាយពេល 2 ម៉ោង និង 6 នាទីលើការងារនេះ ។ គម្លាតខុសគ្នានេះ បានចាក់ឫសនៅក្នុងតួនាទីយេនឌ័រ តាំងពីបុរាណកាល ហើយត្រូវការកិច្ចអន្តរាគមន៍ដើម្បីលើកកម្ពស់សមធម៌ជាងនេះ ក្នុងការបែងចែកការងារទំនួលខុសត្រូវក្នុងការងារថែទាំ ដែលមិនទទួលបានប្រាក់កម្រៃ។
- **ផលប៉ះពាល់លើការបែងចែកពេលវេលារបស់ស្ត្រី៖** ក្នុងមួយថ្ងៃ ស្ត្រីចំណាយពេល 3 ម៉ោង ច្រើនជាងបុរស លើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដែលជាការរឹតត្បិតឱកាសរបស់ពួកគាត់ក្នុងការទទួលបានការអប់រំ ការអភិវឌ្ឍផ្ទាល់ខ្លួន និងវិជ្ជាជីវៈ។ កង្វះពេលវេលានេះ ជាការរឹតត្បិតចំពោះការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ដែលរារាំងដល់ការពង្រឹងភាពអង់អាចរបស់ពួកគាត់ និងជាការរួមចំណែកដល់វិសមភាពយេនឌ័រ។
- **ការងារថែទាំកុមារជាសកម្មភាពការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដែលចំណាយពេលវេលាខ្លាំងជាងគេបំផុត៖** ការងារថែទាំកុមារកើនឡើងខ្លាំងបំផុតនៅចន្លោះម៉ោង ៤-៦ ល្ងាច ដែលរារាំងយ៉ាងខ្លាំងដល់លទ្ធភាពរបស់ស្ត្រីក្នុងការចូលរួមក្នុងការងារដែលមានប្រាក់កម្រៃ ឬសកម្មភាពផ្សេងទៀត ដែលបញ្ហានេះធ្វើឲ្យគម្លាតយេនឌ័រកាន់តែធ្ងន់ធ្ងរថែមទៀត។
- **ការបង្វែរទំនួលខុសត្រូវលើការងារថែទាំតាមជំនាន់៖** និន្នាការនៃការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារដែលមានប្រាក់កម្រៃជារឿយៗតែងបង្វែរទំនួលខុសត្រូវលើការងារថែទាំទៅឲ្យស្ត្រីវ័យចំណាស់ ជាពិសេសចាស់ជរា ដែលជារឿងប៉ះពាល់ដល់សុខភាព និងសុខុមាលភាពរបស់ពួកគាត់។



ស្ត្រីវ័យក្មេង
អាយុ 18-24 ឆ្នាំ
ចំណាយពេលវេលាច្រើនជាងគេបំផុតលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ




គ្រួសារប្រជាពលរដ្ឋ
ប្រើប្រាស់ឧបករណ៍អតិពលកម្ម ដូចជា ចង្ក្រានដុតអុស និងកាធុន សម្រាប់បោកសម្លៀកបំពាក់

## កត្តាដែលជះឥទ្ធិពល

- **ភាពខុសគ្នាតាមអាយុ៖** ស្ត្រីវ័យក្មេង (អាយុ ១៨-២៤ ឆ្នាំ) ចំណាយពេលវេលាច្រើនជាងគេបំផុតលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ចំណែកឯក្នុងចំណោមមនុស្សប្រុសវិញ បុរសវ័យកណ្ដាល (អាយុ ៣៥-៣៩ ឆ្នាំ) ជាអ្នករួមចំណែកការងារនេះច្រើនជាងគេបំផុត ប៉ុន្តែនៅតែតិចជាងស្ត្រីដដែល។
- **ភាពខុសគ្នាតាមភូមិសាស្ត្រ៖** ស្ត្រីរស់នៅទីក្រុងនៃខេត្តសៀមរាប និងស្ត្រីរស់នៅជនបទក្នុងខេត្តកំពត ចំណាយពេលវេលាច្រើនជាងគេបំផុតលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដែលរងឥទ្ធិពលដោយសារលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ សេវាគាំទ្រ និងឱកាសសេដ្ឋកិច្ចក្នុងមូលដ្ឋានរបស់ខ្លួន។
- **ប្រាក់ចំណូល និងពេលវេលាលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ៖** គ្រួសារដែលមានចំណូលកាន់តែខ្ពស់ចំណាយពេលរឹតតែតិចលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ដោយសារលទ្ធភាពទទួលបានឧបករណ៍សន្សំសំចៃពេលវេលា និងជំនួយពីខាងក្រៅ ចំណែកឯគ្រួសារដែលមានចំណូលកាន់តែទាបចំណាយពេលរឹតតែច្រើន ធ្វើឲ្យគម្លាតសេដ្ឋកិច្ចនៅតែបន្តកើតមាន។
- **ការពឹងផ្អែកលើឧបករណ៍បុរាណ៖** គ្រួសារប្រជាពលរដ្ឋចំនួន ៧៤% ប្រើប្រាស់ឧបករណ៍អតិពលកម្ម ដូចជាចង្ក្រានដុតអុស ហើយ ៧៥% ប្រើកាធុនសម្រាប់បោកសម្លៀកបំពាក់ ដែលបង្កើនការចំណាយពេលវេលា និងការខិតខំប្រឹងប្រែងរឹតតែខ្លាំងសម្រាប់កិច្ចការប្រចាំថ្ងៃ។
- **ឧបសគ្គផ្នែកហិរញ្ញវត្ថុដើម្បីទិញឧបករណ៍ទំនើប៖** ភាពមានតម្លៃសមរម្យនៅតែជាឧបសគ្គធំសម្រាប់គ្រួសារមានចំណូលទាប ដែលជាការរារាំងដល់ការប្រើប្រាស់ឧបករណ៍ទំនើបៗដែលអាចសម្រាលការទទួលខុសត្រូវលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។
- **ភាពមានតម្លៃសមរម្យ និងភាពអាចទុកចិត្តបាននៃសេវាថែទាំ៖** ភាពមានកម្រិតនៃលទ្ធភាពទទួលបានសេវាថែទាំ ដែលមានតម្លៃសមរម្យ និងអាចទុកចិត្តបាន ដាក់បន្ទុកកាន់តែធ្ងន់លើទំនួលខុសត្រូវរបស់ស្ត្រីក្នុងការងារថែទាំ ដែលក្នុងនោះអ្នកឆ្លើយតបចំនួនតែ ១០% ប៉ុណ្ណោះ បានរាយការណ៍ថា មានលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ ការងារថែទាំបែបនេះ។
- **ភាពមិនគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រការងារថែទាំ៖** តំបន់ជាច្រើនខ្វះមណ្ឌលថែទាំរឹងមាំ សម្រាប់កុមារ ចាស់ជរា និងជនមានពិការភាព ដែលនាំឲ្យស្ត្រីនានា មានជម្រើសតិចតួចក្នុងការបែងចែកឡើងវិញនូវទំនួលខុសត្រូវរបស់ពួកគាត់លើ ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។
- **បទដ្ឋានយេនឌ័រដែលចេះតែបន្តកើតមាន៖** ការរំពឹងទុករបស់សង្គមបែបប្រពៃណី កំណត់ថាការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ជាការងាររបស់ស្ត្រី ដែលត្រង់នេះរឹតត្បិតដល់ការបែងចែកឡើងវិញនូវការងារទំនួលខុសត្រូវទាំងនេះ បើទោះបីជាសង្គមមានវឌ្ឍនភាពឆ្ពោះទៅរកសមធម៌ក្ដី។
- **សក្ដានុពលនៃការកែប្រែឥរិយាបថ៖** យុទ្ធនាការលើកកម្ពស់ការយល់ដឹង ការអប់រំ និងជនគំរូ អាចជំនះលើផ្នត់គំនិត និង

លើកកម្ពស់ការទទួលខុសត្រូវរួមបាន។ អ្នកឆ្លើយជាបុរសចំនួន ៣២% បានរាយការណ៍ថា “ច្បាប់ប្រុស” ក្រមប្រតិបត្តិសម្រាប់បុរស) ពុំមានឥទ្ធិពលលើការយល់ឃើញរបស់ខ្លួន ទាក់ទិននឹងតួនាទីការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃឡើយ ខណៈដែល ៥២% បានទទួលស្គាល់ថា ទទួលរងផលប៉ះពាល់ក្នុងកម្រិតណាមួយពីច្បាប់ប្រុសនេះ។

- **គុណតម្លៃរួម និងការចង់បានហេដ្ឋារចនាសម្ព័ន្ធ៖** ប្រជាពលរដ្ឋជាច្រើនចង់ឱ្យសេវាថែទាំរួមមាន ការថែទាំកុមារ និងការថែទាំចាស់ជរា នៅជិតផ្ទះរបស់ខ្លួន ដែលឆ្លុះបញ្ចាំងឲ្យឃើញអំពីតម្លៃវប្បធម៌នៃភាពនៅជិត និងការជឿជាក់លើការរៀបចំការថែទាំ ដែលគេស្គាល់។

## អំណាចក្នុងការសម្រេចចិត្ត



ស្ត្រីចំនួន **60%** គ្រប់ដណ្តប់លើការសម្រេចចិត្តចំពោះការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ

- **ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ជាឧបសគ្គចំពោះការពង្រឹងភាពអង់អាច៖** វិសមភាពនៃទំនួលខុសត្រូវលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ បន្ថយភាពជាម្ចាស់ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ដោយរឹតត្បិតលើពេលវេលា និងថាមពលរបស់ពួកគាត់ រឹតត្បិតឱកាសរបស់ពួកគាត់ក្នុងការចូលរួមក្នុងការងារដែលមានប្រាក់កម្រៃ ការអប់រំ ឬសកម្មភាពសង្គម និងនយោបាយជាដើម។
- **ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ជាដែនគ្រប់គ្រងការសម្រេចចិត្តរបស់ស្ត្រី ក្នុងគ្រួសារ៖** ស្ត្រីគ្រប់ដណ្តប់លើការសម្រេចចិត្តចំពោះការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ (៦០%) និងការទិញដូរតិចតួចប្រចាំថ្ងៃ (៧៦%) ចំណែកឯការសម្រេចចិត្តធំដុំជាងនេះ ត្រូវធ្វើឡើងរួមគ្នាជាមួយនឹងស្វាមីរបស់ខ្លួន។ គួរកត់សម្គាល់ថាស្ត្រីចំនួន ៧០% បានរាយការណ៍ថា បានធ្វើការសម្រេចចិត្តដោយខ្លួនឯងចំពោះការចំណាយពេលវេលារបស់ខ្លួន។

## សុខុមាលភាព និងឧបសគ្គពេលវេលា



ស្ត្រីចំនួន **52%** រាយការណ៍ថា មានអារម្មណ៍តានតឹង ដោយសារតែការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ

**ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ជាបន្ទុកផ្លូវចិត្តរបស់ស្ត្រី៖** ភាពធ្ងន់ធ្ងរ និងវិសមភាពនៃទំនួលខុសត្រូវលើការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ជាការប៉ះពាល់ដល់ផ្លូវចិត្ត និងអារម្មណ៍របស់ស្ត្រី។ ស្ត្រីចំនួន ៥២% រាយការណ៍ថា មានអារម្មណ៍តានតឹង ដោយសារតែការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ធៀបនឹងបុរសដែលមានតែ ២២% ប៉ុណ្ណោះ ដែលត្រង់នេះ ឆ្លុះបញ្ចាំងឲ្យឃើញពីទំនាក់ទំនងគ្នារវាងការងារថែទាំដែលមិនទទួលបានប្រាក់កម្រៃ និងសុខុមាលភាពផ្លូវចិត្ត និងអារម្មណ៍របស់ស្ត្រី។

# អនុសាសន៍គោលនយោបា

ដើម្បីជំរុញវឌ្ឍនភាពនៃសមភាពយេនឌ័រ តាមរយៈការដោះស្រាយផលប៉ះពាល់ពីការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ និងឧបសគ្គចំពោះការពង្រឹងភាពអង់អាចរបស់ស្ត្រី ដូច្នេះការសិក្សានេះសូមលើកជាសំណើរអនុសាសន៍គោលនយោបាយដូចខាងក្រោម

## 1 ពង្រឹងវិធានការមានស្រាប់




- **លើកកម្ពស់ការអនុវត្តគោលនយោបាយឱ្យស៊ីជម្រៅ៖** ពង្រឹងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល ដើម្បីធានាបាននូវសមធម៌ នៃការទទួលបានសេវា និងបរិក្ខារចាំបាច់ ដែលជួយកាត់បន្ថយពេលវេលា និងការខិតខំប្រឹងប្រែង ក្នុងការបំពេញកិច្ចការប្រចាំថ្ងៃ រួមទាំងការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃផងដែរ។ ពង្រីកកន្លែងថែទាំ និងបង្កើនកម្មវិធីបណ្តុះបណ្តាល ដើម្បីគាំទ្រស្ត្រីឲ្យបានចូលរួម ឬចូលរួមឡើងវិញក្នុងជួរកម្លាំងពលកម្ម ដោយផ្តល់សេវាថែទាំកុមារ សេវាថែទាំមនុស្សចាស់ និងជនមានពិការភាពក្នុងតម្លៃសមរម្យ ក៏ដូចជាកម្មវិធីអភិវឌ្ឍជំនាញដែលរៀបចំស្របតាមតម្រូវការរបស់ស្ត្រី។
- **ពង្រីកកម្មវិធីរបបសន្តិសុខសង្គម៖** បន្តការពង្រីកគ្រប់ដណ្តប់នៃបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ដល់អ្នកធ្វើការងារក្រៅប្រព័ន្ធ និងបុគ្គលស្វ័យនិយោជន៍ រាប់បញ្ចូលទាំងអ្នកដែលចូលរួមក្នុង ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃផង ដោយផ្តល់ការការពារផ្នែកសង្គមកិច្ចសំខាន់ៗ និងអត្ថប្រយោជន៍នានា ដល់ស្ត្រីដែលជាញឹកញាប់ខ្វះលទ្ធភាពទទួលបានគម្រោងការងារផ្លូវការ។
- **ពិចារណាចំពោះតម្រូវការជាក់លាក់របស់ស្ត្រី៖** នៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ ចូរកំណត់ទិសដៅច្បាស់លាស់ និងមានសមធ៌យេនឌ័រ ហើយប្រមូលទិន្នន័យបែងចែកតាមភេទ ដើម្បីធានាថាស្ត្រីទទួលអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើមទាំងនេះ។ ពង្រឹងភាពអង់អាចរបស់ស្ត្រី តាមរយៈការផ្តល់ជំនាញ ធនធាន និងឱកាសឲ្យពួកគាត់បានចូលរួមពេញលេញនៅក្នុងសង្គម និងសេដ្ឋកិច្ច។

## 2 លើកកម្ពស់ក្របខ័ណ្ឌ ៥R របស់អង្គការអន្តរជាតិខាងការងារ សម្រាប់ការងារថែទាំសមរម្យ



**លើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តឲ្យមានសកម្មភាព៖** អប់រំភាគីពាក់ព័ន្ធអំពីក្របខណ្ឌ ៥Rs ដែលក្នុងនោះរួមមានការទទួលស្គាល់ (Recognize) គុណតម្លៃ ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ការកាត់បន្ថយ (Reduce) ពេលវេលាចំណាយលើការងារថែទាំ និងការងារផ្ទះ ដែលមិនទទួលបានប្រាក់កម្រៃ តាមរយៈសេវាសាធារណៈ និងបច្ចេកវិទ្យា ការបែងចែកឡើងវិញ (Redistribute) នូវការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃឲ្យកាន់តែស្មើភាពរវាងយេនឌ័រ ការផ្តល់រង្វាន់ (Reward) ដល់បុគ្គលិកថែទាំដោយផ្តល់ឱកាសការងារសមរម្យ និងការធានាឱ្យមានតំណាង (Represent) ការសន្ទនាសង្គម និងការចរចាជាសមូហភាពសម្រាប់បុគ្គលិកថែទាំ។

## 3 ការធ្វើសមាហរណកម្ម ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃទៅក្នុងគោលនយោបាយនានា



**ការធ្វើសមាហរណកម្មគោលនយោបាយជាតិ៖** ធានាថាការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ត្រូវបានបញ្ចូលយ៉ាងច្បាស់លាស់នៅក្នុងគោលនយោបាយជាតិព្រមជាមួយនឹងការប្តេជ្ញាចិត្តដែលអាចធ្វើសកម្មភាពបាន និងការផ្តល់មូលនិធិគ្រប់គ្រាន់។ ប្រការនេះត្រូវស្របតាមមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ”។

## 4 ពង្រីកការសិក្សាអំពីយេនឌ័រក្នុងកម្មវិធីអប់រំ



**ការធ្វើសមាហរណកម្មក្នុងវិស័យអប់រំ៖** បញ្ចូលប្រធានបទសមភាពយេនឌ័រទៅក្នុងកម្មវិធីសិក្សារបស់សាលានៅគ្រប់កម្រិតចាប់ពីថ្នាក់បឋមសិក្សាដល់ឧត្តមសិក្សា ដើម្បីបង្កើនការយល់ដឹង និងលើកកម្ពស់សង្គមឲ្យកាន់តែមានសមធម៌។ ការធ្វើបែបនេះជាការជំនះលើបទដ្ឋាន និងផ្នត់គំនិតយេនឌ័រប្រពៃណី ដែលបង្ខាំងស្រ្តីឲ្យរ៉ាប់រងការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។

## 5 គាំទ្រការវិនិយោគលើការកសាងសេដ្ឋកិច្ចដែលគិតគូអំពីសុខុមាលភាព



**រៀបចំគោលនយោបាយគាំទ្រ៖** បង្កើតគោលការណ៍ណែនាំ និងស្តង់ដារច្បាស់លាស់សម្រាប់សេវាថែទាំ និងការងារផ្ទះ បង្កើតថ្នាលសម្រាប់រៀបចំមុខរបរការងារថែទាំឲ្យក្លាយជាការងារក្នុងប្រព័ន្ធ និងផ្តល់ជូននូវកម្មវិធីបណ្តុះបណ្តាលដែលពាក់ព័ន្ធ។ ធានាថាបទប្បញ្ញត្តិច្បាប់នានា ការពារសិទ្ធិរបស់បុគ្គលិកថែទាំ និងផ្តល់រង្វាន់លើកទឹកចិត្ត ដើម្បីជំរុញការចូលរួម និងការវិនិយោគលើសេដ្ឋកិច្ចដែលគិតគូអំពីសុខុមាលភាព។ ការកសាងសេដ្ឋកិច្ចដែលគិតគូអំពីសុខុមាលភាពដែលរឹងមាំ គឺមានសារៈសំខាន់ដល់ការទទួលស្គាល់ ការឲ្យតម្លៃ និងការបែងចែកឡើងវិញនូវការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ ការលើកកម្ពស់សមភាពយេនឌ័រ និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## 6 ការធ្វើស្ថាប័នូបនីយកម្មនៃការអង្កេតលើការប្រើប្រាស់ពេលវេលា



**ដាក់ឲ្យប្រើប្រាស់ឡើងវិញនូវម៉ូឌុលនៃការបែងចែក និងប្រើប្រាស់ពេលវេលា៖** បញ្ចូលកម្រងសំណួរស្តីពីការប្រើប្រាស់ពេលវេលាទៅក្នុងការអង្កេតថ្នាក់ជាតិនានា ដើម្បីតាមដាននិន្នាការរបស់ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ និងកែលម្អគោលនយោបាយដោយផ្អែកលើភស្តុតាងនានា។ លើកទឹកចិត្តឲ្យមានការស្រាវជ្រាវបន្ថែមស្តីពី ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃនៅទូទាំងប្រទេសកម្ពុជា ដើម្បីពង្រីកការយល់ដឹងឲ្យស៊ីជម្រៅ និងស្វែងរកដំណោះស្រាយប្រកបដោយនវានុវត្តន៍ ដោយផ្តល់ជាព័ត៌មានដល់ការបង្កើតគោលនយោបាយ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងគាំទ្រដល់អ្នកថែទាំដែលមិនទទួលបានប្រាក់កម្រៃ។

## 7 ផ្លាស់ប្តូរផ្នត់គំនិតមហាជន



**ជំរុញការផ្លាស់ប្តូរផ្នត់គំនិត៖** អនុវត្តយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងកម្មវិធីអប់រំដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ និងជំនះលើបទដ្ឋានយេនឌ័រដែលរារាំងសមភាពយេនឌ័រ។ កសាងទំនុកចិត្តលើសេវាដែលផ្តល់ដោយអ្នកដទៃ តាមរយៈការលើកកម្ពស់ស្តង់ដារគុណភាព បទប្បញ្ញត្តិ និងសីលធម៌វិជ្ជាជីវៈក្នុងវិស័យថែទាំនេះ ។

## 8 ពង្រីកឱកាសសេដ្ឋកិច្ច



**កំណើនការងារប្រកបដោយបរិយាបន្ន៖** ផ្តល់ឱកាសសម្រាប់ការងារមានផលិតភាព ដែលផ្តល់ប្រាក់ចំណូលសមរម្យ សុវត្ថិភាពនៅកន្លែងធ្វើការ ការគាំពារសង្គម ឱកាសល្អប្រពៃសម្រាប់ការអភិវឌ្ឍផ្ទាល់ខ្លួន និងសមាហរណកម្មសង្គម។ ធានាឲ្យបាននូវសមភាពនៃឱកាស និងប្រព្រឹត្តកម្មចំពោះស្រ្តីគ្រប់រូប។ វិនិយោគលើកម្មវិធីអប់រំ និងបណ្តុះបណ្តាលដែលរៀបចំស្របតាមតម្រូវការ និងសេចក្តីប្រាថ្នារបស់ស្រ្តី ដោយដោះស្រាយនូវឧបសគ្គផ្សេងៗ ដូចជាការរើសអើងយេនឌ័រ និងទំនួលខុសត្រូវមិនសមាមាត្រសម្រាប់ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។

## 9 ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ



**ចែករំលែកការយល់ដឹង៖** ផ្សព្វផ្សាយលទ្ធផលបានពីការស្រាវជ្រាវអំពីការងារថែទាំគ្រួសារ និងការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញការស្វែងយល់កាន់តែប្រសើរក្នុងចំណោមភាគីពាក់ព័ន្ធនានា រួមមានទីភ្នាក់ងាររដ្ឋាភិបាល អ្នករៀបចំគោលនយោបាយ អង្គការសង្គមស៊ីវិល និងមហាជន អំពីការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។ ការធ្វើបែបនេះជំរុញឲ្យមានកិច្ចសន្ទនា ការតស៊ូមតិ និងការបង្កើតគោលនយោបាយផ្អែកលើព័ត៌មានសម្រាប់ការងារថែទាំ និងការងារផ្ទះដែលមិនទទួលបានប្រាក់កម្រៃ។

*"ការស្ទង់មតិ និងការសិក្សានេះ ត្រូវបានធ្វើឡើងដោយ Analytics and Insights Asia ក្នុងអំឡុងខែសីហា-វិច្ឆិកា ២០២៤។*
*របាយការណ៍ពេញនឹងមានលើគេហទំព័រអង្គការអុកស្វាម https :/ cambodia.Oxfam.org ។*